ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ....៨៦៣០...អពដ

GENERAL DEPARTMENT OF TAXATION

L202301160424TD3887

ថ្ងៃព្រហស្បតិ៍១០រោច ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកែសម្រួលនីតិវិធីនៃការបោះពុម្ពប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំ និងនីតិវិធីក្រោយបង់ប្រាក់ពន្ធ លើការកំណត់ពន្ធឡើងវិញ ឬបំណុលពន្ធ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រីជាអភិបាល បណ្ណាធិការ ឬម្ចាស់សហគ្រាស ធនាគារពាណិជ្ជដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាធារណជនជ្រាបថា ក្នុងគោលបំណងផ្តល់ភាពងាយស្រួល និងស្របតាមទំនើបកម្មនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អគ្គនាយកដ្ឋានពន្ធដារបានកែសម្រួលការបោះពុម្ពប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំ និងនីតិវិធីក្រោយបង់ប្រាក់ពន្ធ លើការកំណត់ពន្ធឡើងវិញ ឬបំណុលពន្ធ ដូចខាងក្រោម៖

- **នីតិវិធីនៃការបោះពុម្ពប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំ មាន ០២ ជម្រើស៖**
  ១. ករណីបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំដោយផ្ទាល់ នៅធនាគារពាណិជ្ជដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បុគ្គលិកធនាគារនឹងបោះពុម្ពប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំលើសន្លឹកក្រដាសពណ៌សទំហំ A4 ដោយធនាគារនឹងគិតកម្រៃសេវា "៤ ០០០ រៀល" ឬបោះពុម្ពនៅរដ្ឋបាលសារពើពន្ធដោយឥតគិតកម្រៃសេវា។
  ២. ករណីបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំតាមអនឡាញ លោក លោកស្រីអាចបោះពុម្ពប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំ ចេញពីប្រព័ន្ធគ្រប់គ្រងបង់ប្រាក់ពន្ធតាមអនឡាញ (E-Payment System) បានដោយខ្លួនឯង ដោយពុំចាំបាច់ទៅធនាគារ ឬរដ្ឋបាលសារពើពន្ធដើម្បីបោះពុម្ពទៀតឡើយ។

- **នីតិវិធីក្រោយបង់ប្រាក់ពន្ធ លើការកំណត់ពន្ធឡើងវិញ ឬបំណុលពន្ធ (បង់ផ្តាច់ ឬជំណាក់កាល)**

បន្ទាប់ពីលោក លោកស្រីបានបង់ប្រាក់ពន្ធ លើការកំណត់ពន្ធឡើងវិញ ឬបំណុលពន្ធ (បង់ផ្តាច់ ឬជំណាក់កាល) ជោគជ័យ តាមរយៈប្រព័ន្ធអនឡាញក្តី ឬបង់ដោយផ្ទាល់នៅធនាគារក្តី អគ្គនាយកដ្ឋានពន្ធដារមិនតម្រូវឱ្យយកបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធទៅអង្គភាពគ្រប់គ្រងសហគ្រាស បោះត្រា **"បានចំណូល"** ដើម្បីបញ្ជាក់ស្ថានភាពទូទាត់ប្រាក់ពន្ធទៀតនោះទេ។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីជាអភិបាល បណ្ណាធិការ ឬម្ចាស់សហគ្រាស ធនាគារពាណិជ្ជដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះ ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

*សម្រាប់ព័ត៌មានបន្ថែមអាចទំនាក់ទំនងទូរស័ព្ទមក GDT Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android ឬតាមរយៈ Telegram Channel* ***ព័ត៌មានពន្ធដារកម្ពុជា*** *(https://t.me/gdtcambodianews)*

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**

ស្កេន QR CODEនេះដើម្បីចូល
Telegram Channel
ព័ត៌មានពន្ធដារកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

លេខ/N°PTM23012601825 អពជ



# ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ ២០២២
## អ្នកជាប់ពន្ធមធ្យម

ឈ្មោះសហគ្រាស៖ ក្រុមហ៊ុនសាកល្បង7134
លេខអត្តសញ្ញាណកម្មសារពើពន្ធ៖ K007-9022XXXXX
ចុះបញ្ជីនៅ៖ អគ្គនាយកដ្ឋានពន្ធដារ ស្ថិតនៅក្រោមការគ្រប់គ្រង៖ សាខាពន្ធដារខណ្ឌមានជ័យ
ទ្រង់ទ្រាយសហគ្រាស៖ សហគ្រាសឯកបុគ្គល
សកម្មភាពអាជីវកម្មចម្បង៖ សណ្ឋាគារនិងសណ្ឋាគាររីសត
អាសយដ្ឋានសហគ្រាស៖ #174 ផ្លូវ9040 ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
ឈ្មោះម្ចាស់សហគ្រាស៖ មន ចាន់រដ្ឋធីន សញ្ជាតិ៖ ខ្មែរ

# PATENT TAX 2022
## Medium Taxpayer

Company's name : Companytest1125
Tax Identification Number (TIN) : K007-9022XXXXX
Registered at : General Department of Taxation Under : Mean Chey Tax Branch
Main business activity(ies) : test
Forms of business : Sole proprietorship
Owner's name : MORN CHANROTHIN Nationality: Cambodian

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣
Phnom Penh,26 January 2023

អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation
បោះពុម្ពនៅ / Printed

ទឹកប្រាក់ពន្ធប៉ាតង់ ២០២២
១,២០០,០០០ រៀល
លេខ SN: 900081662
900081663

បញ្ជាក់ ៖ ប័ណ្ណប៉ាតង់នេះត្រូវដាក់តាំង ឬព្យួរ នៅទីកន្លែងប្រកបអាជីវកម្ម។
Note : This patent tax must be hanged or displayed at the company's office.

SAMPLE